អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Jan-2018, 13:15
CMS/CFO: Sann Rada

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/TC

| **កែលើឯកសារលេខ៖** | **ERN(s):** | **កាលបរិច្ឆេទ៖** | **ប្រភេទកំណែ៖** |
|---|---|---|---|
| E3/1360 | 01218822-01218824 | 22/01/2018 | ☐ កែលើឯកសារដើម<br>☒ កែលើឯកសារបកប្រែ<br>☐ រៀបចំទាត់ថ្នាក់ឡើងវិញ |

**មូលហេតុនៃការកែតម្រូវ៖**

ជំនួសឯកសារមិនទាន់កែតម្រូវដោយឯកសារដែលបានកែតម្រូវរួច។

**សេចក្តីលម្អិតនៃការកែតម្រូវ៖**

ស្នើដោយ៖អង្គភាពបកប្រែភាសា ហត្ថលេខា៖

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ ហត្ថលេខា៖

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ ហត្ថលេខា៖

**ចម្លើយសារភាពរៀបរាប់អំពីការឈ្លានពានរបស់សាធារណរដ្ឋសង្គមនិយមវៀតណាមនៅតាកែវ**

សេវាឃោសនាការក្នុងស្រុក ផ្សាយចេញពីទីក្រុងភ្នំពេញ BK020434Y ម៉ោង ២៣:00 GMT ម៉ោងនៅកម្ពុជា ថ្ងៃទី ១ ខែ មីនា ឆ្នាំ ១៩៧៨ BK

[ការសារភាពដោយអនុសេនីយ៍ត្រីទីពីរវៀតណាម (ហា វ៉ានហាច) - កត់ត្រាទុកជាភាសាវៀតណាមដោយមានការបកប្រែផ្ទាល់មាត់ជាភាសាខ្មែរព្រមគ្នា]

[សម្រង់] ខ្ញុំឈ្មោះ (ហា វ៉ាន់ហាច)។ ខ្ញុំអាយុ ២៥ ឆ្នាំ។ ខ្ញុំកើតនៅភូមិវិញទ្រឿង ឃុំចូវផុង ស្រុកភីចូវ ខេត្តអានយ៉ាង។

ខ្ញុំបានចូលរួមក្នុងសម្ព័ន្ធយុវជនរំដោះជាតិហូជីមិញនៅឃុំចូវផុងក្នុងឆ្នាំ ១៩៧១ ជាមួយនឹង (បាយ ឡិញ) ដែលជាមេបញ្ជាការយោធាឃុំ និង (បាយ ចូវ) ដែលជាប្រធានជនស៊ីវិលឃុំ ជាអ្នកធានាខ្ញុំ។ ខ្ញុំបានក្លាយជាសមាជិកនៃបក្សពលករវៀតណាមនៅក្នុងឆ្នាំ ១៩៧៣ ជាមួយ (បាយ ឡិញ) ដែលជាមេបញ្ជាការយោធាឃុំ និង (ប៊ុយ វ៉ានបង) ដែលជាប្រធានបច្ចុប្បន្ននៃទីក្រុងចូវដុក ជាអ្នកធានាខ្ញុំ។ ខ្ញុំមានឋានៈជាអនុសេនីយ៍ត្រីផ្កាយមួយ។ ខ្ញុំបម្រើជាមេបញ្ជាការនៃកងអនុសេនាតូចលេខ ២ នៃអនុសេនាធំលេខ ៤ កងអនុសេនាតូចលេខ ១ កងវរសេនាធំលេខ ៣ កងពលធំលេខ ៤។

ខ្ញុំត្រូវបានចាប់ខ្លួននៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ នៅមាត់ប្រឡាយកំពង់ក្រសាំង នៅក្បែរភូមិក្តុលជំរំ ស្រុកកោះអណ្តែត នៅក្នុងទឹកដីកម្ពុជា។

ចាប់ពីខែ មេសា ដល់ខែ កក្កដា ឆ្នាំ ១៩៧៧ បន្ទាប់ពីបញ្ចប់បេសកកម្មតាមមូលដ្ឋានរបស់ខ្ញុំ ខ្ញុំបានចូលរួមក្នុងវគ្គនយោបាយ និងយោធានៅចូវដុក។ វរសេនីយ៍ឯកផ្កាយមួយ (ហៃ ដាវ) ជាអ្នកគ្រប់គ្រងការហ្វឹកហាត់នេះ។

ដោយថ្លែងពីបក្សកុម្មុយនីស្តវៀតណាម (ហៃ ដាវ) បាននិយាយថា៖ បក្សយើងបានប្តូរឈ្មោះជាច្រើនដង។ ថ្វីបើមានការផ្លាស់ប្តូរឈ្មោះម្តងហើយម្តងទៀតក៏ដោយ ក៏មាគ៌ាបក្សយើងនៅដដែល។ មាគ៌ានេះបានអំពាវនាវឱ្យមានបដិវត្តន៍ដើម្បីរំដោះប្រទេសវៀតណាម កម្ពុជា និងឡាវ និងការបង្កើតសហព័ន្ធឥណ្ឌូចិនក្រោមការគ្រប់គ្រងរបស់វៀតណាម។ (ហៃ ដាវ) បានបន្ថែមថា៖ ឥឡូវនេះ វៀតណាមត្រូវបានរំដោះទាំងស្រុងហើយឥណ្ឌូចិនក៏ដូចគ្នាដែរ។ ប៉ុន្តែ ប្រទេសកម្ពុជាកំពុងអនុវត្តតាមមាគ៌ាខុសពីយើង។ ហេតុនេះហើយបានជាយើងគួរតែវាយប្រហារលើប្រទេសកម្ពុជា និងបង្កើតរដ្ឋាភិបាលថ្មីដែលនឹងយល់ស្របជាមួយមាគ៌ាបក្សកុម្មុយនីស្តវៀតណាម។

Original EN: 00169870-00169969
Translated: [00169876-00169878]

**Deleted:** Unrevised translation. A revised translation will be provided by ITU upon request.

ទាក់ទងទៅនឹងស្ថានភាពក្នុងស្រុក (ហៃ ដាវ) បានសង្កត់ធ្ងន់ថា៖ ចាប់តាំងពីការរំដោះ ប្រទេសយើងបានជួបការលំបាកយ៉ាងខ្លាំង។ បញ្ហាដំបូងកើតឡើងពីការតស៊ូរបស់សំណល់កងទ័ពខ្មាំងប្រមូលផ្ដុំឡើងវិញ ដែលកំពុងលាក់ខ្លួននៅក្នុងព្រៃ ឬបង្កប់ខ្លួនក្នុងចំណោមមហាជន និងអ្នកដែលបានញុះញង់ឱ្យមានវិទ្ធង្សនា និងការបះបោរប្រឆាំងនឹងរដ្ឋាភិបាលថ្មី។ បញ្ហាមួយទៀត ដែលស្មុគស្មាញបំផុត គឺវិស័យសេដ្ឋកិច្ច។ ចាប់តាំងពីសង្គ្រាម ប្រជាជនយើងបានប្រឈមមុខនឹងការខ្វះខាត តម្រូវការ និងការចង់បានជាច្រើន។ យើងខ្វះស្បៀងអាហារ ខ្វះថ្នាំពេទ្យ និងវត្ថុចាំបាច់ផ្សេងទៀត។ ជាលទ្ធផល ប្រជាជនយើងជួបប្រទះភាពអត់ឃ្លាន។ (ហៃ ដាវ ) ក៏បាននិយាយដែរថា៖ សង្គមយើងបច្ចុប្បន្នគឺមិនទាន់មានសន្តិសុខទេ។ ជាពិសេស ទង្វើផ្សេងៗនៃការលួចប្លន់ ចោរកម្ម ការសម្លាប់ ការច្រណែន វិវាទនៅក្នុងជួរយុទ្ធជន និងកម្មាភិបាលរបស់យើង ករណីនៃការលម្អៀងផលប្រយោជន៍ផ្ទាល់ខ្លួន និងបញ្ហាសីលធម៌ដូចជាការប្រព្រឹត្តអនាចារ ប្រមឹកស្រា និងការប្រើអំពើហិង្សាគឺមានពាសពេញ។

ទាក់ទងទៅនឹងស្ថានភាពខាងក្រៅវិញ (ហៃ ដាវ) បាននិយាយថា៖ មានទំនាស់យ៉ាងខ្លាំងរវាងយើង និងកម្ពុជា។

បន្ទាប់ពីបញ្ចប់វគ្គនយោបាយ យើងទទួលបានការបណ្ដុះបណ្ដាលពីយុទ្ធសាស្ត្រប្រយុទ្ធ។ នៅពេលបញ្ចប់ ខ្ញុំបានទៅចូលរួមជាមួយអង្គភាពខ្ញុំវិញ។ ចាប់ពីឆ្នាំ ១៩៧៧ ទៅឆ្នាំ ១៩៧៨ អង្គភាពស៊ើបការណ៍របស់ខ្ញុំបានចូលរួមបួនដងនៅក្នុងការឈ្លានពានប្រឆាំងនឹងទឹកដីកម្ពុជានៅក្នុងខេត្តតាកែវ។

លើកដំបូង នៅខែ មេសា ឆ្នាំ ១៩៧៧ អង្គភាពរបស់ខ្ញុំបានចូលរួមជាមួយអង្គភាពផ្សេងទៀតនៃកងពលធំលេខ ៤ ក្នុងការវាយប្រហារលើទឹកដីកម្ពុជា នៅក្បែរប្រឡាយកំពង់ក្រសាំង ស្រុកកោះអណ្ដែតខេត្តតាកែវ។ អង្គភាពយើងរត់ចូលទៅក្នុងចំពួយឫស្សី គ្រាប់មីន និងការបាញ់កាំភ្លើងធំរបស់កងកម្លាំងកម្ពុជា និងត្រូវបានបង្ខំឱ្យដកថយ។ គ្នាយើង ១៥ នាក់បានស្លាប់ និង ១៩ នាក់រងរបួស។

លើកទីពីរ នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៧ អនុសេនាធំនៃកងពលធំលេខ ៤ របស់យើងបានចូលទៅកម្ពុជាដើម្បីសាកសួរអំពីស្ថានភាពយោធានៃភាគីកម្ពុជានៅក្នុងតំបន់ព្រៃសង្គមមានជ័យនៃឃុំព្រៃខ្លា ស្រុកកោះអណ្ដែត ខេត្តតាកែវ។ យើងត្រូវបានបង្ខំដោយការបាញ់កាំភ្លើងធំរបស់កម្ពុជាឲ្យដកថយទៅប្រទេសយើងវិញនៅល្ងាចថ្ងៃដដែល។ នៅពេលនោះ គ្នាយើង ៨ នាក់បានស្លាប់ និង ២០ នាក់រងរបួស។

Deleted: យក

Deleted: Unrevised translation. A revised translation will be provided by ITU upon request.

លើកទីបី នៅខែ តុលា ឆ្នាំ ១៩៧៧ អនុសេនាធំពីររបស់យើងបានចូលទៅប្រទេសកម្ពុជាម្តងទៀតនៅក្នុងតំបន់ព្រៃខ្លា។ យើងត្រូវបានបង្ខំឱ្យដកថយ ដោយសារយើងរត់ចូលទៅក្នុងកងតស៊ូដ៏រឹងមាំដោយភាគីកម្ពុជា។ គ្នាយើង ១៥ នាក់បានស្លាប់ និង ១០ នាក់ផ្សេងទៀតរងរបួស។

លើកទីបួន នៅថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ អង្គភាពរួមបញ្ចូលគ្នា ក្នុងនោះមានទាំងកងអនុសេនាតូចរបស់ខ្ញុំ បានចេញទៅប្រមូលព័ត៌មានក្នុងទឹកដីកម្ពុជា នៅក្បែរភូមិក្តុលជំរំ ស្រុកកោះអណ្តែត ខេត្តតាកែវ។ ក្រុមរបស់យើងមានបុរស ៣០នាក់។ សហមេបញ្ជាការរបស់ខ្ញុំ ដែលជាអនុសេនីយ៍ត្រីផ្កាយមួយ (ដាំ) ខ្ញុំ និងបុរសប្រាំពីរនាក់បានទន្ទ្រានប្រហែល ៣ គីឡូម៉ែត្រចូលទៅក្នុងប្រទេសកម្ពុជា។ អ្នកនៅសល់នៃក្រុមរបស់យើងបានរង់ចាំនៅពីក្រោយ ៣០០ ម៉ែត្រពីព្រំដែន ក្នុងទឹកដីកម្ពុជា។

នៅពេលដែលយើងសម្រាកហូបអាហារថ្ងៃត្រង់ យើងត្រូវបានកងកម្លាំងកម្ពុជាឡោមព័ទ្ធ និងបាញ់មកលើ។ បុរសបីនាក់របស់ខ្ញុំត្រូវបានសម្លាប់។ ខ្ញុំ និងមនុស្សប្រាំនាក់ផ្សេងទៀតបានលើកដៃចុះចាញ់។ យើងត្រូវបានកងកម្លាំងកម្ពុជាចាប់ខ្លួននៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ១៩៧៨។ ពួកទាហានដែលត្រូវបានចាប់គឺ៖ ខ្ញុំ ជាអនុសេនីយ៍ត្រីផ្កាយមួយ (ហា វ៉ាន់ហាច) ពលទាហាន (ហុង) ពលទាហាន (ទុយ) នាយទោ (តាំ)នាយទោល (ថើយ ) និងនាយទោ (ទៀង)។ មនុស្សបីនាក់ដែលបានស្លាប់គឺ អនុសេនីយ៍ត្រីផ្កាយមួយ (ដាំ) ដែលជាមេបញ្ជាការនៃក្រុមនេះ ពលបាលត្រី (ទុង) និងនាយទោ (ហួង)។ កាំភ្លើង AK ប្រាំបួនដើមដែលយើងបាននាំមកជាមួយត្រូវបានរឹបអូស។

ធ្វើនៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៧៨
ហត្ថលេខា៖ (ហា វ៉ាន់ហាច)

Formatted: Condensed by 0.7 pt

Deleted: Unrevised translation. A revised translation will be provided by ITU upon request.